**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣ សលរ

# សារលិខិត

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងឱកាសខួបលើកទី៩ ទិវាជាតិនៃការចងចាំ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦

- **សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់**
- **សូមក្រាបថ្វាយបង្គំ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់**
- **សូមក្រាបថ្វាយបង្គំ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់**
- **សម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ តំណាងរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត និងអង្គការអន្តរជាតិទាំងអស់ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**
- **បងប្អូនជនរួមជាតិ ជាទីស្រលាញ់!**

រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី២០ ខែឧសភា ជា «**ទិវាជាតិនៃការចងចាំ**» សម្រាប់រំឭកដល់ជនរងគ្រោះ និងរំឭកអំពីការឈឺចាប់នៃឧក្រិដ្ឋកម្ម ដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ដើម្បីលើកតម្កើងការគោរពវិញ្ញាណក្ខន្ធ និងការធ្វើបុណ្យឧទ្ទិសដល់ជនរងគ្រោះ ដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, លើកតម្កើងការរំឭកដល់ជនរងគ្រោះ ការស្តារកិត្តិយសនិងសេចក្តីថ្លៃថ្នូរ របស់ជនរងគ្រោះ ទោះជានៅរស់រានមានជីវិតឬបានបាត់បង់ជីវិតក៏ដោយ, ប៉ះប៉ូវការឈឺចាប់ខាងផ្លូវចិត្តនិងផ្នែកសង្គម របស់ជនរងគ្រោះនិងក្រុមគ្រួសារ, ចូលរួមចំណែកដល់ការផ្សះផ្សាជាតិនិងជំរុញឱ្យមានសុខដុមនីយកម្មក្នុងសង្គម កម្ពុជា, និងលើកកម្ពស់ការផ្សព្វផ្សាយ និងការយល់ដឹងអំពីអំពើឃោរឃៅដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កុំឱ្យកើតមានឡើងសាជាថ្មី ហើយប្រជាពលរដ្ឋគ្រប់រូបត្រូវបានផ្តល់ឱកាសឱ្យរៀបចំពិធីតាមជំនឿ សាសនា ឬ ទំនៀមទម្លាប់របស់ខ្លួន។

ដូចជនរួមជាតិបានដឹងហើយថា រដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានអនុម័តយកថ្ងៃទី**២០ ខែឧសភា** ជា «**ទិវាចងកំហឹង**» កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨៣ ដើម្បីជាការចងកំហឹងចំពោះ «**បនប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី និងខៀវ សំផន**» ដែលបានកាប់សម្លាប់ ជិះជាន់ និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ លើប្រជាជនកម្ពុជា ហើយត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ១៩៨៤មក។ ក្រោយឆ្នាំ១៩៩៣ រាជរដ្ឋាភិបាល

កម្ពុជាបានប្តូរពី «**ទិវាចងកំហឹង**» ទៅជា «**ទិវាចងចាំ**» រហូតដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១៩ អនក្រ.បក កំណត់យកថ្ងៃទី**២០ ខែឧសភា** ជា «**ទិវាជាតិនៃការចងចាំ**» វិញ ដោយមានមូលហេតុចម្បងចំនួនពីរ៖ **ទី១-** ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ គឺជាថ្ងៃបង្កើត **សហករណ៍** ដើម្បីប្រមូលផ្តុំប្រជាជនធ្វើការងារក្រុមសាមគ្គី ដោយលុបបំបាត់កម្មសិទ្ធិឯកជន នៅក្នុងតំបន់មួយចំនួនដែលហៅថាតំបន់រំដោះដែលស្ថិតក្រោមការគ្រប់គ្រងនៃកងទ័ពរំដោះខ្មែរក្រហម និង**ទី២-** អតីតក្រុមមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត និង នួន ជា បានរៀបចំផែនការនិងប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាទ្រង់ទ្រាយធំ ដែលធ្វើឱ្យប្រជាជនកម្ពុជាប្រមាណជាង៣លាននាក់ បានស្លាប់ក្នុងរបបដ៏ឃោរឃៅយង់ឃ្នងនេះ។

ជាង៣ទសវត្សរ៍ចុងក្រោយនេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ស្ថាបនិកនយោបាយឈ្នះ ឈ្នះ ព្រះរាជាណាចក្រកម្ពុជាបានប្រែក្លាយជាប្រទេសមានសុខសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី ឯករាជ្យជាតិ និងអធិបតេយ្យភាពពេញបរិបូរណ៍ ដែលមិនធ្លាប់មានជាង៥០០ឆ្នាំ ក្នុងប្រវត្តិសាស្ត្រចុងក្រោយនេះ។ ទន្ទឹមនឹងនេះ ក្រោមដំបូលនៃសុខសន្តិភាព ប្រទេសកម្ពុជាក៏បានកែប្រែពីប្រទេសដែលខ្ទេចខ្ទាំដោយសារសង្គ្រាម ទៅជាសង្គមសម័យទំនើប ដោយផ្តល់ជាគំរូក្នុងការស្ថាបនាសន្តិភាព ការបញ្ចៀសជម្លោះ និងការបង្កើតឱ្យមានតុលាការគំរូមួយសម្រាប់ពិភពលោក និងបានកាត់ក្តីអតីតមេដឹកនាំខ្មែរក្រហមប្រកបដោយជោគជ័យ ព្រមទាំងបានចារឹកជាស្លាកទុកក្នុងប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប៖ **សន្តិភាពតាមរយៈយុត្តិធម៌ផ្សះផ្សាជាតិ និងយុត្តិធម៌ផ្សះផ្សាជាតិក្នុងគោលដៅសន្តិភាព**។ ឆ្លងតាមលទ្ធផលនៃការបញ្ចប់ដំណើរការតុលាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ទទួលបានយុត្តិធម៌ កិត្តិយស និងសេចក្តីថ្លៃថ្នូរក៏ត្រូវបានស្តារឡើងវិញ ព្រមទាំងទទួលបាននូវការប៉ះប៉ូវចំពោះការឈឺចាប់ខាងផ្លូវចិត្តនិងផ្នែកសង្គម ដោយទទួលស្គាល់គម្រោងសំណងចំនួន២៦ ក្នុងនោះក៏មានទិវាជាតិនៃការចងចាំផងដែរ។

បន្ទាប់ពីបញ្ចប់ការជំនុំជម្រះក្តី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តកិច្ចការសេសសល់ ហើយក្នុងនោះបានប្រែក្លាយជាមជ្ឈមណ្ឌលធនធាន អ.វ.ត.ក. ដើម្បីចូលរួមដល់ការចងចាំ ការថែរក្សាសន្តិភាព សាមគ្គីភាព ការអប់រំនិងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយ ក្នុងគោលបំណងទប់ស្កាត់កុំឱ្យឧក្រិដ្ឋកម្មបែបនេះកើតឡើងសាជាថ្មី។ មជ្ឈមណ្ឌលធនធាន អ.វ.ត.ក. នេះបង្កើតឡើងដើម្បីផ្តល់ជនរងគ្រោះ ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី ជាវេទិកាជួបជុំ និងធ្វើសកម្មភាពមួយចំនួន។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលធនធាន អ.វ.ត.ក. បើកទូលាយដល់សាធារណជន តាមរយៈ (១) បណ្ណាល័យនិងកន្លែងស្រាវជ្រាវ, (២) និហិតដ្ឋានបណ្ណសារដែលតម្កល់ឯកសារកាត់ក្តីប្រមាណជាង ២,៥លានទំព័រ សម្រាប់បម្រើផលប្រយោជន៍អប់រំនិងស្រាវជ្រាវ, (៣) បន្ទប់ប្រើប្រាស់ពហុបំណងសម្រាប់រៀបចំសិក្ខាសាលានិងតុលាការប្រឌិត, (៤) បន្ទប់ពិគ្រោះយោបល់សម្រាប់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មកស្វែងរកការពិតនិងចែករំលែកបទពិសោធឈឺចាប់ដល់យុវជនជំនាន់ក្រោយ, (៥) សាលតាំងពិព័រណ៍អចិន្ត្រៃយ៍ស្តីពីដំណើរការជំនុំជម្រះក្តី និង(៦) ឧទ្យានសម្រាប់ការចងចាំ ដែលជាកន្លែងសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម និងសាធារណជនមកជួបជុំនិងចែករំលែកបទពិសោធ ឆ្លុះបញ្ចាំងពីអ្វីដែលបានកើតឡើង និងរំឭកដល់វិញ្ញាណក្ខន្ធអ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ ជាទស្សនវិស័យវែងឆ្ងាយក្នុងគោលដៅពង្រឹងនិងថែរក្សាសន្តិភាពយូរអង្វែងនៅកម្ពុជា និងការចែករំលែកបទពិសោធដែលទទួលបានដ៏លំបាករបស់កម្ពុជា ទាក់ទងនឹងដំណោះស្រាយក្រោយជម្លោះ ការកសាងសន្តិភាព ការបង្ការនិងការទប់ស្កាត់ឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅ និងយុត្តិធម៌អន្តរកាលទៅថ្នាក់តំបន់និងសកលលោក រាជរដ្ឋាភិបាលនឹងរក្សាកេរដំណែល បណ្ណសារដែលមានសច្ចភាពប្រវត្តិសាស្ត្រ និងឧត្តមានុវត្តន៍របស់ អ.វ.ត.ក. ឱ្យស្ថិតស្ថេរគង់វង្សសម្រាប់ជាប្រយោជន៍ដល់អ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ និងយុវជនជំនាន់ក្រោយ។

ឆ្នាំ២០២៦ នេះជាលើកទី៩ នៃការប្រារព្ធទិវាជាតិនៃការចងចាំ ២០ ឧសភា ហើយក៏ជាលើកទី៤៣ បើរាប់ចាប់ពីឆ្នាំ១៩៨៤ មក ដែលទិវានេះបានចូលរួមចំណែកក្នុងការផ្សះផ្សាជាតិ ជំរុញឱ្យមានសុខដុមនីយកម្ម និងលើកកម្ពស់ការយល់ដឹងអំពីអំពើឃោរឃៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីទប់ស្កាត់កុំឱ្យអំពើបែបនេះកើតមានឡើងសាជាថ្មី។ ដើម្បីចូលរួមលើកកម្ពស់ការចងចាំ និងដោះស្រាយការឈឺចាប់របស់ជនរងគ្រោះ សកម្មភាពជាច្រើនត្រូវបានធ្វើឡើង រួមទាំងការប្រារព្ធទិវានេះនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ទីតាំងពិឃាតនៅតាមបណ្តាស្រុក រាជធានី ខេត្តនានា និងនៅមជ្ឈមណ្ឌលធនធាន អ.វ.ត.ក. ។ល។

ជាមួយនឹងការរំឭកខួបលើកទី៩ **ទិវាជាតិនៃការចងចាំ ២០ ឧសភា** ឆ្នាំ២០២៦នេះ យើងទាំងអស់គ្នាត្រូវរួមគ្នាថែរក្សាការពារសន្តិភាពឱ្យបានគង់វង្ស ព្រោះសន្តិភាពជាមូលដ្ឋានសម្រាប់ការកសាងគ្រួសារ សហគមន៍ និងប្រទេសជាតិឱ្យមានការអភិវឌ្ឍ រីកចម្រើន ស្ថិរភាព និងសន្តិសុខ។ សព្វថ្ងៃនេះ កម្ពុជាកំពុងរស់នៅក្រោមម្លប់សន្តិភាព មានស្ថិរភាពនយោបាយ ស្ថិរភាពសង្គម និងការអភិវឌ្ឍ។ សមិទ្ធផលទាំងនេះ កើតចេញពីការខិតខំប្រឹងប្រែងរួមគ្នារបស់រាជរដ្ឋាភិបាលនិងប្រជាជាតិទាំងមូល ក្នុងការថែរក្សាសន្តិភាព ការផ្សះផ្សាជាតិ និងការលើកកម្ពស់ស្មារតីសាមគ្គីភាពជាតិ។ ក្នុងបរិបទដែលពិភពលោកកំពុងប្រឈមនឹងជម្លោះ អំពើហិង្សា និងភាពមិនប្រាកដប្រជាខ្ពស់ កម្ពុជាកាន់តែយល់ច្បាស់អំពីតម្លៃដ៏ថ្លៃថ្លានៃសន្តិភាពនិងស្ថិរភាពនៅក្នុងសង្គម ហើយក៏ជាអ្វីដែលកម្ពុជាត្រូវចងចាំនិងយល់ដឹងឱ្យបានកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រនិងអត្តសញ្ញាណពិតប្រាកដរបស់ខ្លួនផងដែរ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយនិងប្រគេនពរសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** និងសូមថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គ មានព្រះរាជសុខភាពមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់សម្រាប់កូនចៅ ចៅទួតរបស់ព្រះអង្គ យូរអង្វែងតរៀងទៅ និងសូមប្រសិទ្ធពរជ័យជូន សម្តេច ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី បងប្អូនជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរបួនប្រការ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៣កើតខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**